ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០០៥.....សហវ.ភ្នាល

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៨

## សេចក្តីជូនដំណឹង

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជំរាបជូនដំណឹងដល់ក្រុមហ៊ុន ឬអ្នកវិនិយោគដែលជារូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងអស់អោយបានជ្រាបថា រាជរដ្ឋាភិបាលសំរេចអោយ ក្រុមហ៊ុន ឬ អ្នកវិនិយោគដែលជារូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងឡាយណា ដែលទទួលបានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល (សជណ) ដើម្បីធ្វើអាជីវកម្ម ល្បែងកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (ស្លុតម៉ាស៊ីន) ហើយ តែមិនទាន់បានដំណើរការអាជីវកម្ម ត្រូវរួសរាន់ មកបំពេញបែបបទស្នើសុំអាជ្ញាប័ណ្ណធ្វើអាជីវកម្ម នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេល០៦ ខែ គិតចាប់ពី ថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ដំណាច់ខែកក្កដា ឆ្នាំ២០០៨។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងឈប់ផ្តល់អាជ្ញាប័ណ្ណ ស្លុតម៉ាស៊ីនជូនក្រុមហ៊ុនស្លុតម៉ាស៊ីន ថ្មីហើយ។

ទទួលបានសេចក្តីជូនដំណឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹម និងជឿជាក់ថា លោកនាយក/នាយិកាក្រុមហ៊ុន ឬ អ្នកវិនិយោគដែលជារូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងអស់ នឹងខិតខំអនុវត្តតាមការណែនាំនេះ អោយទទួលបានប្រសិទ្ធភាពខ្ពស់ ។

សូមលោកនាយក/នាយិកាក្រុមហ៊ុន ឬអ្នកវិនិយោគដែលជារូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងអស់ ទទួលនូវការរាប់អានពីខ្ញុំ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន :**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-គ្រប់សាលាខេត្ត-ក្រុង
"ជ្រាបជាពត៌មាន"
-ឯកសារ-កាលប្បវត្តិ